# ចរិត ក្បត់ សម្ដី

សម្ដី ទោះបី ចង់បង្ហាញ នូវ ទឹកចិត្តល្អ តែ វា ផ្ទុយពី ចរិត ដែល បានធ្វើ វាជា ការបោកប្រាស់។ ដូចយ៉ាង ឯកឧត្ដមខ្លះ និយាយ ថា ‹‹ ខ្ញុំមិនយកខ្មែរណា ជា សត្រូវ ›› តែ យក សត្រូវ របស់ខ្មែរ ជា មិត្ត វាជា ចរិត ក្បត់នឹង សម្ដី។ បើ និយាយថា ‹‹ ខ្ញុំ ជា អ្នក បង្រួបបង្រួមខ្មែរ ›› តែ បែរ ទៅចូលរួម ជាមួយ ជនផ្ដាច់ការ គឺ ជា សម្ដី កុហក។ នៅស្រុកខ្មែរ សព្វថ្ងៃ របបក្រុងភ្នំពេញ គេ និយាយ សម្ដី ទន់ភ្លន់ ទៅកាន់ ប្រជាជន តែ ដៃ កាន់ ដំបង វាយ ក្បាល ជនខ្មែរ គ្មានជម្រក ដើម្បី ការពារ ផលប្រយោជន៏ ឧកញ៉ា គឺ ជា អំពើ ថោកទាប។ ទោះបី ខំ បញ្ជាក់ថា ចង់ឱ្យតែ ខ្មែរសុខ តែ ពុំមើលឃើញ ទុក្ខ របស់ខ្មែរ គឺជា ការស្រមើស្រមៃ។ ជនយួន នៅពេញស្រុក តែ និយាយថា ជនខ្មែរ មាន សន្តិភាព គឺជា មនុស្សឆ្កួត។ បើ នាំគ្នា អួត ថា ស្រុកខ្មែរ ជា ប្រទេស ជឿន លឿន គឺជា ក្រុមមនុស្ស ទុក ចិន និង យួន ជា វាសនាខ្មែរ។ តែ បើ ជនខ្មែរ ទាំងឡាយ និយាយថា ខ្លួន ជា ជនរងគ្រោះ នៃ របបផ្ដាច់ការ តែ នាំគ្នា ដេក រង់ចាំ មហាប្រទេស លោកសេរី មកជួយរំដោះ គឺជា ការធ្វើអត្តឃាតកម្ម។ រង់ចាំ កិម សុខា បង្រួបបង្រួមខ្មែរ គឺនាំគ្នា ជឿ ខ្មោច ថាមានពិត។ គិត សង្ឃឹម លើ សម រង្ស៊ី មកសង្គ្រោះជាតិ គឺជា ការអស់សង្ឃឹម នៅក្នុង ជីវិត។ បើ មាន គំនិត ល្អ តែ ជា មហាត គឺ ច្បាស់ ជា ប្រើគំនិត នោះ សំរាប់ បំរើ ផលប្រយោជន៏ ទុច្ចរិត៕